ពេលវេលា នៃការសក ?

តាំងពីឆ្នាំ ១៩៩១ មក ប្រជាពលរដ្ឋខ្មែរ រង់ចាំ ការសក នៃរបបនយោបាយចាស់ តាមការកំណត់ នៃកិច្ចព្រមព្រៀងសន្តិភាព នាថ្ងៃទី២៣ តុលា ឆ្នាំ ១៩៩១។ តែជាការរង់ចាំស្ពុក តែក៏មិនបានគិតថា វាខកខាន ដ្បិតមានឧបស័គ្គអ្វីមួយរារាំង។ កង្វះនេះ វាជាពេលវេលាគ្រោះថ្នាក់ និង គួរឱ្យបារម្ភ : « សង្ឃឹមថា លោកចាស់ស្លាប់បាត់ទៅហើយ តែ លោកថ្មី ក៏មិនលេចចេញជារូបរាងដែរ »។ មែនពិត ប្រជាពលរដ្ឋខ្មែរនាំគ្នា ចូលរួមក្នុងដំណើរការប្រជាធិបតេយ្យ តាមការបោះឆ្នោត ដោយមានជំនឿថា វាគ្រប់គ្រាន់សំរាប់ ផ្សាំប្រជាធិបតីនៅស្រុកខ្មែរ តែភ្លេចគិតថា ក្បៀណនោះ តួអង្គសំខាន់ៗ[1] នៃលោកចាស់អាយុខែជាអ្នកបន្តធ្វើជានាយកថ្មី គ្មានការយល់ដឹងអំពីបញ្ហាប្រឈម[2] អាចនាំមក នូវស្មារតីថ្មី នៃការផ្លាស់ប្តូរចាំបាច់វិធីសាស្ត្រដឹកនាំជាតិ ព្រោះគំនិតសុខុម ជាទព្វសម្ភារៈ ដែលត្រូវរចនា ដើម្បីបំបែកអារ្យធម៌កខ្វក់ ពីគំនិត នៃតួអង្គចាស់ទាំងនោះ ដែលធ្លាប់ដើរនៅលើផ្លូវអពមង្គល វាមិនទាន់លេចធ្លោ ជាបច្ច័យ។ កំហាននេះ គឺជាឫសគល់ នៃអកុសលនៅស្រុកខ្មែរ : ប្រត្យក្សភាព នៃសភាវគតិ នៃអំពើហឹង្សានៅមានច្រើនក្រៃលែង ដើម្បីឲជឿជាក់ថា របបដឹកនាំសព្វថ្ងៃកំពុងដើរលើផ្លូវ នៃវឌ្ឍនភាព ដើម្បីប្រជារាស្ត្ររីករាយនៅក្នុងសន្តិភាពមង្គល៕

---

[1] សម្តេចសីហនុ និង ពួកខ្មែរក្រហមនិយមយួន និង ចិន។
[2] បញ្ហាប្រឈម, Défi។